**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

**រវាង**

**រោងចក្រ ថប ស៊ីលវើរ លីមីធីត**

**និង**

**តំណាងប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋានប្រចាំ**

**រោងចក្រ ថប ស៊ីលវើរ លីមីធីត**

**ស្តីអំពីការព្យួរកិច្ចសន្យាការងារ**

នៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០២២ វេលាម៉ោង០៨ និង ៣០នាទីព្រឹក នៅក្នុងក្រុមហ៊ុន **ថប ស៊ីលវើរ លីមីធីត ( ត្បូងឃ្មុំ )** មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិត សហជីពមូលដ្ឋានប្រចាំក្រុមហ៊ុន ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារតែក្រុមហ៊ុនយើងបច្ចុប្បន្នប្រឈមមុខខ្លាំងនឹងបញ្ហា ជំងឺកូវីដ-១៩ ឥវ៉ាន់ដែលបានធ្វើរួចហើយត្រូវអ្នកបញ្ជាទិញមិនទាន់ទទួលតាមការកំណត់ ដោយហាងលក់ទំនិញភាគច្រើននៅបរទេសមិនទាន់បើកទ្វារនៅឡើយទេ ដែលចំណុចទាំងអស់នេះធ្វើអោយផលិតកម្មមួយផ្នែកធំមិនមានការងារធ្វើ តម្រូវអោយមានការព្យួរការងារ។ ហេតុដូចនេះក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ៨៥៧នាក់ ចាប់ពីថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០២២ រហូតដល់ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២២ ។ នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ កម្មករនិយោជិតបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុនតាមលក្ខខណ្ឌដូចខាងក្រោម ។

- ចំនួន ១០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ចំនួន ២០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ចំនួន ៣០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ២១ថ្ងៃ ដល់ ០១ខែ។

អង្គប្រជុំបានចប់វេលាម៉ោង ១០ និង៣០នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងរលូន ។

ត្បូងឃ្មុំ.ថ្ងៃទី១៨ ខែមករា ឆ្នាំ ២០២២

| **តំណាងកម្មករ និង តំណាងសហជីព** | **នាយកក្រុមហ៊ុន** |
|---|---|